

GRET
Professionals for Fair Development

# ALiSEA បណ្ដាញសិក្សាស្វែងយល់ពីក្សេត្របរិដ្ឋាននៅតំបន់អាស៊ីអាគ្នេយ៍

## ការផ្ដួចផ្ដើមគំនិតថ្មីមួយក្នុងតំបន់

ជាមួយនឹងការកើនឡើងយ៉ាងលឿននៃចំនួនមនុស្ស ការកើនឡើងនូវសំពាធទៅលើធនធានធម្មជាតិ និងវត្តមាន កាន់តែច្បាស់នៃផលប៉ះពាល់បណ្ដាលមកពី បម្រែបម្រួលអាកាសធាតុនាពេលបច្ចុប្បន្ន តំបន់អាស៊ី អាគ្នេយ៍ត្រូវស្ថិតនៅក្នុងរបត់មួយនៅក្នុងការអភិវឌ្ឍន៍កសិកម្ម ។ ការអនុវត្តន៍ក្សេត្របរិដ្ឋាន ផ្ដល់នូវជម្រើសដែលអាចជឿជាក់បានដល់ប្រព័ន្ធកសិចំណីអាហារបច្ចុប្បន្ន ។

ថ្វីបើមានគំនិតផ្ដួចផ្ដើមជាច្រើនដែលគាំទ្រការអភិវឌ្ឍន៍ក្សេត្របរិដ្ឋាន និងតួអង្គទាំងឡាយក្នុងតំបន់ មេគង្គក៏ដោយ ក៏នេះគឺជាកិច្ចខិតខំប្រឹងប្រែងថ្មីតំបូងសំដៅរៀបបណ្ដាញ នៃតួអង្គទាំងនេះ ទាំងកម្រិតជាតិ និង កម្រិត តំបន់ ដើម្បីបង្កើតនូវសម្ពន័ភាពរឹងមាំមួយ នៃតួអង្គពាក់ពន្ធ័ក្នុងកំរិតផ្សេងៗគ្នា - ចាប់ពីអង្គការកសិកររហូតដល់មជ្ឈមណ្ឌលស្រាវជ្រាវថ្នាក់ជាតិ និងថ្នាក់តំបន់ និងរួមបញ្ជូលនូវផ្នែកឯកជន ដែលទាំងនេះអាចជួយជំរុញ គោលនយោបាយសាធារណៈ និងបញ្ចុះបញ្ជូលឲ្យតួអង្គពាក់ព័ន្ធ នានាគាំទ្រកាន់តែខ្លាំងថែមទៀត ដល់ការផ្សព្វផ្សាយយ៉ាងទូរលំទូលាយនូវជម្រើសនៃការអនុវត្តកសិកម្ម ដែលទទួលបានជោគជ័យ។

## ការអនុវត្តន៍បន្តពីការពិគ្រោះយោបល់ជាមួយតួអង្គពាក់ព័ន្ធ

មុនការចាប់ផ្ដើមគម្រោង គឺមានការសំយោគបញ្ចូលគ្នារវាងការសិក្សាឯកសារនានានិងលទ្ធផលសិក្ខាសាលាពិគ្រោះយោបល់តាមប្រទេសនីមួយៗ (ប្រទេសឡាវ ភូមា វៀតណាម និងកម្ពុជា)។

សិក្ខាសាលានេះគឺការបំពេញបន្ថែមដោយការបង្ហាញ និងពិភាក្សាគ្នាលើលទ្ធផលបឋម (នៃការសិក្សាឯកសារ) ជាមួយតួអង្គពាក់ព័ន្ធនានាដែលធ្វើការងារលើក្សេត្របរិដ្ឋានក្នុងប្រទេសនិមួយៗ ។

នៅក្នុងប្រទេសទាំង៤ យើងបានរកឃើញមានដៃគូរដែលមានសក្ដានុពលសរុបចំនួន ១១៨ (អង្គការក្រៅរដ្ឋាភិបាល ស្ថាប័នស្រាវជ្រាវ ទីភ្នាក់ងាររដ្ឋាភិបាល និងក្រុមហ៊ុនឯកជន) ដែលយើងរំពឹងទុកថានឹងធ្វើឲ្យបណ្ដាសម្បូរទៅដោបទពិសោធន៍ផ្សេងៗគ្នាជាច្រើននាថ្ងៃអនាគតដូចជា៖ កសិកម្មអភិរក្ស កសិរុក្ខកម្ម ប្រព័ន្ធប្រពលវប្បកម្មស្រូវ វិធានការចម្រុះគ្រប់គ្រងកត្ដាចង្រៃ កសិកម្មសរីរាង្គ ការកសិកម្មចំរុះជាដើម ។



## គោលបំណងរបស់ ALiSEA

⇒ ពង្រឹងចំណេះដឹង និងចែករំលែកបទពិសោធន៍ក្នុងចំណោមគំនិតផ្ដួចផ្ដើម និងតួអង្គដែលធ្វើការលើក្សេត្របរិដ្ឋាន

⇒ បង្កើនភាពជឿជាក់ និងភាពអាចមើលឃើញកាន់តែច្បាស់នៃចលនាក្សេត្របរិដ្ឋានចំពោះអ្នកបង្កើតគោលនយោបាយ និងអ្នកបរិភោគ

⇒ ពង្រីកការអភិវឌ្ឍន៍ និងការទទួលយកបច្ចេកទេសក្សេត្របរិដ្ឋានមកអនុវត្តនៅក្នុងចំណោមកសិករ

## ការចាប់ដៃគូរជាមួយ CIRAD

ALiSEA គឺជាសមាសភាគមួយនៃកម្មវិធីធំមួយដែលមានឈ្មោះថា ការគាំទ្រដំណើរឆ្ពោះទៅកាន់ ក្សេត្រដ្ឋាននៅក្នុងតំបន់មេគង្គ (ACTAE) ។ កម្មវិធីនេះសម្របសម្រួលដោយ CIRAD ដែលក៏ជាអ្នកទទួល ខុសត្រូវលើសមាសភាគផ្សេងទៀតដែលផ្ដោតទៅលើបណ្ដាញកសិកម្មអភិរក្ស ក្នុងតំបន់អាស៊ីអាគ្នេយ៍ (CANSEA)



## ជំហានសំខាន់ៗដែលត្រូវអនុវត្ត

> បង្កើតគេហទំព័រវេទិកាថ្នាក់តំបន់ស្តីអំពីកសិអេកូឡូស៊ី (ALiSEA website)
> ធ្វើការសិក្សាដើម្បីរៀបចំផែនទីបង្ហាញអំពីការអនុវត្តន៍ និងបទពិសោធន៍នានាលើក្សេត្របរិដ្ឋាន និងបណ្តាញផ្សេងៗក្នុងប្រទេសទាំង ៤
> រៀបចំការវាយតម្លៃរួមគ្នាលើការអនុវត្តក្សេត្របរិដ្ឋាន និងបទពិសោធន៍នានា (ករណីសិក្សាផ្សេងៗ) ជាមួយនិងការវិភាគពីលក្ខន័ក្នុងការពង្រីកបន្ថែម។
> ទាក់ទាញ និងជំរុញឲ្យមានការសិក្សាស្រាវជ្រាវកំរិតវិទ្យាសាស្រ្ត
> រៀបចំសិក្ខាសាលាជាមួយតួអង្គពាក់ព័ន្ធនានានៅថ្នាក់ជាតិ អន្តរជាតិ ដើម្បីចែករំលែកបទពិសោធន៍ បំពេញភាពខ្វះចន្លោះ និងជំរុញភាពបំពេញគ្នាទៅវិញទៅមក
> បង្កើត និងអនុវត្តការផ្តល់ជាជំនួយថវិកាខ្នាតតូច ដែលជាការផ្តល់បដិភាគដើម្បី ភ្ជាប់ជាបណ្តាញរវាង តួអង្គពាក់ព័ន្ធនានា
> បង្កើតក្រុមប្រឹក្សាអ្នកជំនាញក្នុងកំរិតប្រទេស
> គាំទ្រលេខាដ្ឋានថ្នាក់ជាតិដែលទទួលដោយដៃគូរនានាក្នុងប្រទេសនិមួយៗ



## លទ្ធផលជាគំបូចដែលទទួលបានពីការសិក្សារៀបចំបង្កើតគម្រោង

- នៅក្នុងតំបន់មេគង្គមានគំនិតផ្តួចផ្តើមនិងបទពិសោធន៍ជាច្រើនស្តីអំពីការអនុវត្តន៍ដែលរួមចំណែកធ្វើឲ្យមានការឆ្ពោះទៅកាន់ក្សេត្របរិដ្ឋាន
- ភាពទាន់សម័យ នៃទស្សនទានអំពីក្សេត្របរិដ្ឋានគឺសំអាងលើចំណេះដឹងដែលផ្អែកលើបទពិសោធន៍ និងការកើនឡើងនៃការយល់ដឹងផ្នែកវិទ្យាសាស្រ្ត ព្រមទាំងប្រើប្រាស់សម្រាប់ដំណើរការប្រពលវប្បកម្មកសិកម្មនិរន្តភាព
- ផ្នែកផ្សេងៗនៃក្សេត្របរិដ្ឋានដែលមានស្រាប់គឺទទួលបាននូវការដឹងលឺ ប៉ុន្តែការវាយតម្លៃក្នុងកម្រិតតំបន់ទៅលើប្រសិទ្ធភាពនៃការអនុវត្តបច្ចេកទេសកំរិតនៃការទទួលយកការគ្របដណ្តប់ និងការសាយភាយនៃការអនុវត្តនានា
- សំខាន់គឺការផ្សព្វផ្សាយ និងការគាំទ្រ មិនត្រូវផ្តោ តតែទៅលើជម្រើសបច្ចកកសិកម្មប៉ុណ្ណោះទេ ត្រូវផ្តោតលើវិធីសាស្រ្តផ្សព្វផ្សាយថែមទៀតផង
- សារៈសំខាន់នៃការដោះស្រាយបញ្ហានៃការធ្វើឲ្យ ផលិតផលមានតម្លៃ ការអនុវត្តបច្ចេកទេស និង/ ទិន្នភាពនានា (វិញ្ញាបត្រទទួលស្គាល់ ប្រព័ ធានាដោយមានការចូលរួម ផ្លាសសញ្ញា PGS)
- ចែករំលែកអត្ថប្រយោជន៍សម្រាប់បំពេញភាពខ្វះ ចន្លោះ និងជំរុញភាពបំពេញគ្នាទៅវិញទៅមក ដើម្បីផ្លាស់ប្តូរ និងបង្កើនបទពិសោធន៍សំដេ បង្កើនភាពកាន់តែមើលឃើញ ចំពោះការអនុវ និងពង្រីកនូវការទទួលយកបច្ចេកទេសដោយ កសិករ ព្រមទាំងរួមបញ្ចូលទៅក្នុងគោលនយេ បាយសារធាណៈ



ការធ្វើថ្នាំពុលផ្សំពីស្លឹកស្មៅ (ការគ្រប់គ្រងកត្តាចង្រៃ)



ប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវតាមគោលការធម្មជាតិ



កសិរុក្ខកម្ម



ការដាំបន្លែចំរុះ

## ចំរុះភាពនៃការអនុវត្តកសិកម្មក្សេត្របរិដ្ឋាន

ថវិកាចំនួន ១.២ លានអឺរ៉ូ ត្រូវបានផ្តល់ដោយទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍន៍ (AFD)

AGENCE FRANÇAISE DE DÉVELOPPEMENT

គំនិតឬមតិផ្សេងៗដែលបានបង្ហាញ នៅទីនេះគឺជារបស់អង្គការផ្ទាល់ ហើយមិនសុទ្ធតែតំណាងឲ្យគំនិតរបស់ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍន៍នោះឡើយ ។

ប្រធានគម្រោងប្រចាំតំបន់គឺ លោក. Pierre Ferrand អ៊ីម៉ែល: ferrand@gret.org

អ្នកសម្របសម្រួលប្រទេសភូមាគឺ លោក. Htet Kyu, អ៊ីម៉ែល: htekyu@gret.org

អ្នកសម្របសម្រួលប្រទេសកម្ពុជាគឺ កញ្ញា. Lucie Reynaud, អ៊ីម៉ែល: reynaud@gret.org

អ្នកសម្របសម្រួលប្រទេសឡាវគឺ លោក. Saythong Vilayvong, អ៊ីម៉ែល:vilayvong2003@gmail.com

www.gret.org